ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២២៥

ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២

សាលដីកា

លេខ : ១៧៨ "ឈ"

ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ជាសាធារណៈ

នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ដោយមានសមាសភាពដូចតទៅ ៖

-ឯកឧត្តម [redacted] ជាប្រធាន

-លោក [redacted] ជាចៅក្រម

-លោក [redacted] ជាចៅក្រម

-លោក [redacted] ជាចៅក្រម

-លោក [redacted] ជាចៅក្រម

-លោក [redacted] ជាក្រឡាបញ្ជី

តំណាងមហាអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញា

លើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ១៥ ក្រIV "ច" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១៣២ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ រវាង ៖

-<u>ដើមចោទ</u> : ឈ្មោះ[redacted] នោម (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្នភូមិបឹងខ្នារ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិសាត់ ប្រពន្ធឈ្មោះ [redacted] ឃឹម មានកូន ០៥ នាក់។

.មានលោក[redacted] ជាមេធាវីតំណាងដោយអាណត្តិ

-<u>ចុងចម្លើយ</u> :

១-ឈ្មោះ[redacted] ទី (ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិស្នាលមាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ប្តីឈ្មោះ[redacted] យីវ មានកូន ០៤ នាក់។

២-ឈ្មោះ [redacted] ធុន (ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៦៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិកោះស្វាយ ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិសាត់ ប្តីឈ្មោះ [redacted] ធួក មានកូន ០៤ នាក់។

.មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

<u>កម្មវត្ថុបណ្តឹង</u> : ដើមចោទប្តឹងសុំសាលក្រម ៖

- បញ្ឈប់ការជួលដីស្រែទំហំ ៦ ហិកតា ពីចុងចម្លើយ ។
- បង្គាប់ឲ្យចុងចម្លើយប្រគល់ដីស្រែទំហំ ៦ ហិកតា ។

-តាមបណ្តឹងសាទុក្ខលេខ ២៩១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] ទី ,ឈ្មោះ [redacted] ធុន ,ឈ្មោះ [redacted] ធួក ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ ១៥ ក្រIV "ច" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសម្រេចនៃសាលដីកាទាំងមូល។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២២៥ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ របស់តុលាការកំពូល។

-កាលពីអំឡុងឆ្នាំ២០០៣ ចុងចម្លើយឈ្មោះ [redacted] ធួក ប្រពន្ធឈ្មោះ [redacted] ធុន និងឈ្មោះ [redacted] យើវ ប្រពន្ធឈ្មោះ [redacted] ទី ដែលជាក្រុមគ្រួសារឪពុក-ម្តាយ និងកូន បានខ្ចីប្រាក់របស់ឈ្មោះ [redacted] អោម ជាដើមចោទ ដើម្បីយកទៅជួញដូរសត្វគោ-ក្របីទៅវៀតណាម ដោយរកស៊ីខាតបង់ មិនអាចរកប្រាក់សងបំណុលទៅឲ្យដើមចោទវិញ។ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៣ ចុងចម្លើយ ឈ្មោះ [redacted] យើវ និងប្រពន្ធឈ្មោះ [redacted] ទី បានលក់ដីស្រែទំហំ ២០.០០០ ម$^2$ (ពីរម៉ឺនម៉ែត្រការ៉េ) តម្លៃ ៤.០០០.០០០ (បួនលានរៀល) មកឲ្យដើមចោទឈ្មោះ [redacted] អោម (មានឯកសារបញ្ជាក់) និង ក្រោយមកទៀតនៅក្នុងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦ ចុងចម្លើយឈ្មោះ [redacted] ធួក និងប្រពន្ធឈ្មោះ [redacted] ធុន ត្រូវជាឪពុកម្តាយបង្កើតរបស់ចុងចម្លើយឈ្មោះ [redacted] យើវ បានលក់ដីស្រែទំហំ ៤០.០០០ ម$^2$ (បួនម៉ឺនម៉ែត្រការ៉េ) មកឲ្យដើមចោទឈ្មោះ [redacted] អោម ទៀត (មានឯកសារបញ្ជាក់) ដើម្បីកាត់ ប្រាក់ជំពាក់។ ក្រោយពីទិញរួច ដើមចោទបានជួលដីស្រែទាំងពីរកន្លែងនោះទៅឲ្យចុងចម្លើយឈ្មោះ [redacted] យើវ និងប្រពន្ធឈ្មោះ [redacted] ទី ធ្វើស្រែទាំង ៦ (ប្រាំមួយហិកតា) ដោយយកឈ្នួលក្នុងមួយហិកតា ជាស្រូវទំងន់ ៤០០ គីឡូក្រាម (មានឯកសារបញ្ជាក់)។ ចុងចម្លើយឈ្មោះ [redacted] យើវ និងប្រពន្ធឈ្មោះ [redacted] ទី បានឲ្យឈ្នួលស្រែជារៀងរាល់ឆ្នាំ លើកលែងតែនៅក្នុងឆ្នាំ២០១០ ចុងចម្លើយនៅខ្វះឈ្នួលស្រែ ចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) បន្ទាប់មកថា ឈប់ឲ្យឈ្នួលនៅឆ្នាំបន្តទៀតមកឲ្យ ដើមចោទ ដោយអះអាងថា មិនប្រគល់ដីស្រែនោះមកឲ្យដើមចោទទេ ព្រោះខ្លួនមិនបានលក់ឲ្យ

៧៤៨



Scanned with CamScanner

ដើមចោទ។ ក្រោយពីលក់ដីរួច ចុងចម្លើយនៅជំពាក់បំណុលដើមចោទ ដែលបានខ្ចីមួយចំនួនទៀត ដើមចោទទាមទារឲ្យចុងចម្លើយសងប្រាក់ ជំពាក់សរុបទាំងប្រាក់ខ្ចី និងប្រាក់ឈ្នួលស្រែចំនួន ១៧.៥០០.០០០ រៀល (ដប់ប្រាំពីរលានប្រាំរយពាន់រៀល) ដែលចុងចម្លើយមិនទាន់បានសង។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៦ "ជ" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តពោធិសាត់ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១១ និងទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] ឆោម ចុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់។

២-ក/បង្គាប់ឲ្យឈ្មោះ [redacted] ធួក និងប្រពន្ធឈ្មោះ [redacted] ធុន ប្រគល់ដីស្រែទំហំ ៤០.០០០ (បួនម៉ឺន) ម៉ែត្រការ៉េ នៅភូមិស្នាល់មាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ដែលមានព្រំប្រទល់ ៖

- ខាងជើងទល់នឹងឈ្មោះ ណូម
- ខាងត្បូងទល់នឹងផ្លូវរទេះ
- ខាងកើតទល់នឹងដីឈ្មោះ តាភឿន
- ខាងលិចទល់នឹងថ្នល់ ទៅឲ្យដើមចោទឈ្មោះ [redacted] ឆោម។

ខ/បង្គាប់ឲ្យឈ្មោះ [redacted] យឹវ និងប្រពន្ធឈ្មោះ[redacted]ទី ប្រគល់ដីស្រែទំហំ ២០.០០០ (ពីរម៉ឺន) ម៉ែត្រការ៉េ នៅភូមិស្នាល់មាន់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិសាត់ ដែលមានព្រំប្រទល់ ៖

- ខាងជើងទល់នឹងដីឈ្មោះ មឹងសឿន
- ខាងត្បូងទល់នឹងឈ្មោះ គ្រួន
- ខាងកើតទល់នឹងដីឈ្មោះ ពូឌុល
- ខាងលិចទល់នឹងដីឈ្មោះ [redacted] ធួក ទៅឲ្យដើមចោទឈ្មោះ [redacted] ឆោម។

គ/បង្គាប់ឲ្យឈ្មោះ [redacted] ធួក ប្រពន្ធឈ្មោះ [redacted] ធុន និងឈ្មោះ [redacted] យឹវ ប្រពន្ធឈ្មោះ[redacted]ទី រួមគ្នាសងប្រាក់ជំពាក់ និងប្រាក់ឈ្នួលស្រែសរុបចំនួន ១៧.៥០០.០០០ (ដប់ប្រាំពីរលានប្រាំសែន) រៀល ទៅឲ្យឈ្មោះ [redacted] ឆោម ជាម្ចាស់បំណុល។

៣-ច្រានចោលការទាមទាររបស់ភាគីចុងចម្លើយឈ្មោះ [redacted] ធួក ប្រពន្ធឈ្មោះ [redacted] ធុន និងឈ្មោះ [redacted] យឹវ ប្រពន្ធឈ្មោះ [redacted] ទី ដែលសុំឲ្យដើមចោទប្រគល់ដីស្រែឲ្យខ្លួនវិញ ដោយសុំសងបំណុលទៅដើមចោទចំនួន ២៥ (ម្ភៃប្រាំលាន) រៀល វិញក្នុងរយៈពេល ២ (ពីរ) ឆ្នាំទៀត។

២៤៤

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៥-សាលក្រមនេះ បញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ចំពោះមុខដើមចោទ និងចុងចម្លើយ។

បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ធ្លូក ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៦ "ផ" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តពោធិសាត់ ត្រង់ចំណុចទាំងមូលនៃសាលក្រមខាងលើ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២០ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ទី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៦ "ផ" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តពោធិសាត់ ត្រង់ចំណុចទាំងមូលនៃសាលក្រមខាងលើ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៥ ក្រIV "ច" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ច្រានចោលពាក្យបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ [redacted] ធ្លូក និង [redacted] ទី ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៦ "ផ" ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តពោធិសាត់ ទុកជាបានការ។

៣-ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted] ធ្លូក និង [redacted] ទី។

-សាលដីកានេះ ទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២។ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេល ១ ខែ គិតពីថ្ងៃទទួលការបញ្ជូនសាលដីកានេះ។

-បានឃើញបណ្តឹងសាទុក្ខលេខ ២៩១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] ទី ,ឈ្មោះ [redacted] ធុន ,ឈ្មោះ [redacted] ធ្លូក ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៥ ក្រIV "ច" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសម្រេចនៃសាលដីកាទាំងមូល។

២៤០



Scanned with CamScanner

-បានឃើញលិខិតបញ្ជាក់ពីមូលហេតុបណ្តឹងសាទុក្ខ របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យម្ចាស់បណ្តឹងសាទុក្ខឈ្មោះ [redacted] ធូក។

-បានឃើញឯកសារត្រៀម (សារណាតប) របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យចុងបណ្តឹងសាទុក្ខឈ្មោះ [redacted] ឆោម។

-បានឃើញឯកសារត្រៀម (សារណាតប) របស់ចុងបណ្តឹងសាទុក្ខឈ្មោះ [redacted] ឆោម។

-បានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ជា

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សំណុំរឿងនេះជាវិវាទឯកជន មិនប៉ះពាល់ប្រយោជន៍សាធារណៈទេ សូមសំរេច។

## ដំណាក់កាលទាញហេតុផលផ្ទាល់មាត់

-អ្នកស្រី [redacted] ធុន ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖

[redacted] ទី ជាកូនរបស់ខ្លួន វានៅឆ្ងាយមិនបានមក។ ដីនេះ ខ្លួនមិនបានលក់ទេ គឺបញ្ចាំប៉ុណ្ណោះ បញ្ចាំ ៣ ឆ្នាំ ទេ ពេលខ្លួនទៅលោះ ដើមចោទថា ដីគាត់។ ការពិតជារឿងបញ្ចាំ គាត់ដាក់ក្នុងលិខិតថា លក់ គ្រាន់តែដាក់ទេ គាត់ថា មានលុយសង ឲ្យដីខ្លួនវិញ ពេលផ្តិតៗជាមួយគ្នា [redacted] ធូក ផ្តិតមេដៃដែរ។ កិច្ចសន្យាជួលស្រែ ខ្លួនមិនដែលជួលទេ បញ្ចាំដំបូង ២ ហិកតា (កូន) ក្រោយខ្លួនបញ្ចាំ ៤ ហិកតា ដីលើកទី ១ បញ្ចាំ ៤ លានរៀល ឯ ៤ ហិកតា ស្មើនឹង ១៥ លានរៀល សរុប ១៩ លានរៀល។ សុំយកដីវិញ។ ដីស្រែខ្លួនធ្វើរហូតទល់សព្វថ្ងៃ។

-លោក [redacted] ឆោម ជាចុងបណ្តឹងសាទុក្ខ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖

ដី ពិតជាចុងចម្លើយលក់ឲ្យខ្លួនមែន ចុះវាស់វែងមុនទិញ មានចុងចម្លើយ កូន និងអន្លង់របស់ចុងចម្លើយចូលរួម។ បើបញ្ចាំមិនដែលគេចុះវាស់វែងទេ។ ឆ្នាំ២០០៣ លក់ ៤ លានរៀល ទិញហើយ ឲ្យកូនចុងចម្លើយធ្វើយកផលចែកគ្នា ១ ហិកតា ម្នាក់ ដល់ឆ្នាំ២០០៧ ខ្លួនធ្វើសំបុត្ររួមចាប់ជួលទាំង ៦ ហិកតា តែម្តង។ ឆ្នាំ២០០៦ ខ្លួនទិញ ៤ ហិកតា ទៀតពីចុងចម្លើយ ពេលទិញហើយ ខ្លួនជួលឲ្យកូន (ចុងចម្លើយ) [redacted] ទី ទេ កូនប្រគល់ដីឲ្យខ្លួនហើយ តែ [redacted] ធុន និង [redacted] ធូក មិនព្រម។ ខ្លួនទិញពេលនោះតាមតំលៃទីផ្សារ គ្មានការបង្ខិតបង្ខំទេ។ ចុងចម្លើយជំពាក់ថ្លៃឈ្នួលខ្លួនតាំងឆ្នាំ២០១០ (២ លានរៀល) និងបន្តដល់សព្វថ្ងៃ។ ថ្លៃឈ្នួលដំបូងយកស្រូវក្រោយមកគិតជាលុយ ១ ហិកតា ៤០០ គីឡូក្រាម ដាក់ស្តែង ១ ហិកតា ថ្លៃ ១ លានរៀល តែ ៤ ហិកតា យកតែ ១ លានរៀលទេ។ លុយ ១៧ លានរៀល លុយទារលើការខាតបង់ និងជំងឺចិត្ត។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា ៖

រឿងក្តីនេះអយុត្តិធម៌ណាស់ សុំឱ្យតុលាការផ្តល់យុត្តិធម៌ឱ្យចុងចម្លើយផង។ ដំបូងកូនទេយកដីរបស់ [redacted] ធូក និង [redacted] ធុន ទៅបញ្ចាំទេ។ បើកិច្ចសន្យាលក់ផ្តាច់មែន ម្តេចមិនឱ្យម្ចាស់ [redacted] ធូក និង [redacted] ធុន ផ្តិតមេដៃផង កូន ([redacted] ទី) មិនមែនម្ចាស់ដីទេ ឯកសារដែល [redacted] ឆោម ដាក់ចូលតុលាការនេះ ជាឯកសារបន្លំ។ ដោយកូនរកស៊ីខាត ក៏ជំពាក់ប្រាក់ដើមចោទដល់ ១៥ លានរៀល ពេលគេរកចាប់កូន ក៏ [redacted] ធូក និង [redacted] ធុន យកដីទៅដាក់ធានាឱ្យដើមចោទចំនួន ១៥ លានរៀលនេះ។ ដើម្បីរកយុត្តិធម៌ សុំឱ្យតុលាការហៅសាក្សីផ្តិតមេដៃលើលិខិតកិច្ចសន្យាទាំងអស់មកសួរបញ្ជាក់។ កិច្ចសន្យាធ្វើឆ្នាំ២០០៣ និង២០០៦ ឯកិច្ចសន្យាជួលឆ្នាំ២០០៧ មេភូមិបញ្ជាក់ឆ្នាំ២០០៨ ឯអ្នកជួលមិនបានផ្តិតមេដៃទេ ចេះតែសរសេរឈ្មោះដាក់ សុំឱ្យតុលាការពិចារណា និងបដិសេធសាលក្រម និងសាលដីកាសាលាឧទ្ធរណ៍ចោល និងកិច្ចសន្យា ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៣ និងចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦ និងចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ និងសុំបង្វិលទៅសាលាឧទ្ធរណ៍សំរេចឡើងវិញ ដើម្បីសួរសាក្សីពាក់ព័ន្ធ។ កិច្ចសន្យាឆ្នាំ២០០៦ មានស្នាមមេដៃ [redacted] យីវ) កូនរបស់ [redacted] ធូក ដាក់ធានាជំនួស។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យចុងបណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា ៖

រឿងនេះ ដំបូងជាការខ្ចីប្រាក់ និងដាក់បញ្ចាំដោយគ្មានលទ្ធភាពសងចុងចម្លើយ យកដីលក់ឱ្យដើមចោទ និងខ្ចីបន្តបន្ទាប់។ កិច្ចសន្យាលក់ផ្តាច់ មានការឯកភាពពីគូភាគីត្រឹមត្រូវ។ ពេលដល់តុលាការកំពូល ចុងចម្លើយបដិសេធផ្ទុយពីជំហរដើមរបស់ខ្លួន។ កិច្ចសន្យាមិនបាននិយាយលំអិតទេ ឯកសារបំពេញពេលក្រោយផ្អែកលើការនិយាយគ្នាជាចំបង។ តាមដើមចោទបញ្ជាក់ថា រាល់ឯកសារ គឺចុងចម្លើយជាអ្នករៀប និងរត់ការឱ្យអាជ្ញាធរ។ ពីតុលាការថ្នាក់ក្រោមចុងចម្លើយមិនបានប្រើសិទ្ធិខ្លួនទេ ដូចនេះការហៅសាក្សីសួរមិនចាំបាច់ឡើយ។ ការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍ ផ្អែកលើភស្តុតាង និងឯកសាររបស់គូភាគីហើយ។ សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីទានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និងមេធាវីតំណាងដោយអាណត្តិរបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

# តុលាការកំពូល

-យល់ឃើញថា : បណ្ដឹងសាទុក្ខលេខ ២៩១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់ភាគីចុងចម្លើយ [redacted]ទី និង [redacted]ធុន ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តពោធិសាត់ ទុកជាបានការ ដោយបង្គាប់អោយចុងចម្លើយប្រគល់ដីស្រែទំនាស់ និងប្រាក់ចំនួន ១៧.៥០០.០០០ រៀល ទៅអោយដើមចោទនោះ មិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ព្រោះថាសាលាឧទ្ធរណ៍មិនបានពិចារណាត្រង់ចំណុច ៖

-កិច្ចសន្យាលក់ផ្ដាច់ដី ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៣ មានការកែតួលេខប្រវែងទទឹង និងផ្ទៃក្រឡាដី។

-កិច្ចសន្យាលក់ផ្ដាច់ដី ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៣ ដីស្រែដែលត្រូវលក់មានបណ្ដោយ ២០០ ម៉ែត្រ និងទទឹង ១០០ ម៉ែត្រ ហើយកិច្ចសន្យាលក់ផ្ដាច់ដី ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០០៦ ដីស្រែដែលត្រូវលក់មានបណ្ដោយ ២០០ ម៉ែត្រ និងទទឹង ២០០ ម៉ែត្រ។ ដីស្រែដែលត្រូវលក់ទាំង ២ នេះ មានទ្រង់ទ្រាយខុសពីរូបរាងដីស្រែជួល ដែលកិច្ចសន្យាជួលស្រែ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ បានកំណត់ច្បាស់ថា ដីស្រែដែលត្រូវជួលមួយកន្លែង មានបណ្ដោយប្រវែង ៦០០ ម៉ែត្រ និងទទឹងប្រវែង ១០០ ម៉ែត្រ។

-កិច្ចសន្យាជួលស្រែ ធ្វើនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ រីឯមេភូមិបញ្ជាក់ថាកិច្ចសន្យាពិតជាបានធ្វើនៅចំពោះមុខខ្លួនប្រាកដមែន តែមានកាលបរិច្ឆេទ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០០៨ ទៅវិញ។

-យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ១៥ ក្រIV "ច" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមក មានលក្ខណៈខុសឆ្គងនឹងគតិច្បាប់។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ ២៩១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់ចុងចម្លើយ [redacted] ទី និង [redacted] ធុន។

២-បដិសេធចោលសាលដីការដ្ឋប្បវេណីលេខ ១៥ ក្រIV "ច" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ២២៥ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ របស់តុលាការកំពូល ត្រឡប់ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ។

៥-សាលដីកានេះ ជំនុំជម្រះ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤។

-ឯកឧត្តម [redacted] ប្រធាន

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ,ថ្ងៃទី២២ ខែឧសភាឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ,ថ្ងៃទី២២ ខែឧសភាឆ្នាំ ២០១៤

ប្រធាន

[redacted]

២៩៤



Scanned with CamScanner